ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សារលិខិតរំលែកទុក្ខ

**សូមគោរពជូន**
**ឯកឧត្តមកិត្តិបរិក្សបណ្ឌិត ហោ ណាំហុង ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងក្រុមគ្រួសារ**

ឯកឧត្តមកិត្តិបរិក្សបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិតជាមានសេចក្តីរន្ធត់ចិត្តឥតឧបមាដោយបានទទួលដំណឹងថា **ឯកឧត្តម ហោ ណាំបូរ៉ា** អតីតឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឥណ្ឌូណេស៊ី ត្រូវជាកូនប្រុសបង្កើតរបស់ **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត** បានទទួលមរណភាពនៅថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ១១:១១នាទីព្រឹក ក្នុងជន្មាយុ ៦៤ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់ **ឯកឧត្តម ហោ ណាំបូរ៉ា** គឺជាការបាត់បង់នូវកូនប្រុសជាទីស្រលាញ់ ស្វាមី និងឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះក្រុមគ្រួសារ ហើយក៏ជាការបាត់បង់នូវឥស្សរជនដ៏ឆ្នើមមួយរូប ដែលបានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីបំពេញការងារប្រកបដោយមនសិការទទួលខុសត្រូវខ្ពស់ និងប៉ិនប្រសព្វក្នុងផ្នែកទំនាក់ទំនងការទូតជូនរាជរដ្ឋាភិបាលរយៈពេលជាងមួយទសវត្សរ៍កន្លងមក។

ក្នុងឱកាសប្រកបដោយសេចក្តីខ្សឹកខ្សួលរំជួលចិត្តដ៏មហាក្រៀមក្រំនេះ ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងនូវសមានទុក្ខប្រកបដោយអនិច្ចលក្ខណធម៌ដ៏មហាជ្រាលជ្រៅ ព្រមទាំងក្តីសង្វេគដ៏មហាធំធេង និងពោរពេញដោយក្តីសោកស្តាយស្រណោះអាឡោះអាល័យជាអនេកប្បការជាមួយ **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត** និងក្រុមគ្រួសារនៃសព និងសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម ហោ ណាំបូរ៉ា** សូមបានទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត ហោ ណាំហុង ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងក្រុមគ្រួសារនៃសព មេត្តាទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំនេះ និងការគោរពយ៉ាងជ្រាលជ្រៅពីយើងខ្ញុំ។

ថ្ងៃ ពុធ ១២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០២៤
រដ្ឋមន្ត្រី

**ហេង សួរ**